UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

# អង្គការសហប្រជាជាតិ

## ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

## សេចក្តីជូនដំណឹងដល់សារព័ត៌មាន

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា
នឹងធ្វើទស្សនកិច្ចមកកម្ពុជា ជាលើកទីពីរ

**កម្មវត្ថុ ៖** ដំណើរទស្សនកិច្ចលើកទីពីររបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា
**អ្នកណា ៖** អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា
**កាលបរិច្ឆេទ ៖** ពីថ្ងៃ១៨ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០
**នៅទីណា ៖** កម្ពុជា

---

អ្នកសារព័ត៌មានទាំងឡាយ

អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក ស៊ូយ៉ា ប្រាសាទ ស៊ូប៉ៃឌី នឹងធ្វើទស្សនកិច្ចមកកម្ពុជា ពីថ្ងៃទី១៨ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០។

នេះជាបេសកកម្មលើកទីពីរមកកម្ពុជារបស់លោក ហើយនឹងផ្តោតទៅលើដំណើរការនៃស្ថាប័នរដ្ឋ ដែលត្រូវលើកស្ទួយនិងការពារសិទ្ធិនានា ដើម្បីធានាឲ្យមានប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាច នីតិប្រតិបត្តិ ព្រមទាំងលើកស្ទួយនិងការពារការអភិវឌ្ឍន៍ប្រជាធិបតេយ្យ។ លោកមានបំណងនឹងប្រើប្រាស់ដំណើរទស្សនកិច្ចនេះ ដើម្បីពិនិត្យអំពីដំណើរការនៃរដ្ឋសភា និងស្ថាប័នតុលាការ ព្រមទាំងស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ។ គោលបំណងរបស់លោក គឺធ្វើការវិភាគថាតើ ស្ថាប័នទាំងនេះដំណើរការយ៉ាងដូចម្តេច ហើយជួយដោះស្រាយដល់ប្រជាពលរដ្ឋបានកំរិតណាចំពោះការរំលោភលើសិទ្ធិរបស់ពួកគេ។

អ្នករាយការណ៍ពិសេសគឺជាអ្នកជំនាញការឯករាជ្យម្នាក់ ដែលត្រូវបានតែងតាំងដោយ ក្រុមប្រឹក្សាសិទ្ធិមនុស្សសហប្រជាជាតិ ដើម្បីតាមដាននិងរាយការណ៍អំពីស្ថានភាពសិទ្ធិមនុស្ស នៅកម្ពុជា។ ភារកិច្ចរបស់លោកគឺដើម្បីវាយតម្លៃអំពីស្ថានភាពសិទ្ធិមនុស្ស និងរាយការណ៍ជាសាធារណៈ និងធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូរផ្សេងៗទៀត ដើម្បីលើកតំកើងកិច្ចសហប្រតិបត្តិការជាអន្តរជាតិក្នុងវិស័យនេះ។ អ្នករាយការណ៍ពិសេសបំពេញទស្សនកិច្ច ឬបេសកកម្មជាទៀងទាត់មកកម្ពុជា ហើយរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សប្រចាំឆ្នាំ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាជួយដល់លោកផ្នែកភស្តុភានិង បច្ចេកទេស។

សំរាប់ព័ត៌មានបន្ថែមអំពី អ្នករាយការណ៍ពិសេស សូមមើលគេហទំព័រ៖ http://cambodia.ohchr.org/EN/PagesFiles/SpecialRapporteurIndex.htm
និងសូមទាក់ទងRiona Judge McCormack, 012790178, rjudgemccormack@ohchr.org ឬ ទូច ហួន htouch@ohchr.org 012 476 493.

---

The Office of the High Commissioner for Human Rights is the principal United Nations agency responsible for the promotion and protection of human rights.

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

United Nations Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia